**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ៦៦៦/២១ ក.ប/សជ.ធ.ឱ.ល

# សេចក្តីណែនាំ
# ស្តីពី
# ការបើកដំណើរការឡើងវិញ
# គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនឯកឧត្តម លោក លោកស្រី នាយក នាយិកា គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ក្រោមឱវាទក្រសួងទាំងអស់ឱ្យបានជ្រាបថា យោងតាមគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងសម្រេចអនុញ្ញាតឱ្យគ្រឹះស្ថាន អ.ប.វ. បើកដំណើរការឡើងវិញ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ដើម្បីអាចទទួលបានការអនុញ្ញាតឱ្យបើកដំណើរការឡើងវិញ គ្រឹះស្ថាន អ.ប.វ. ត្រូវអនុវត្តដូចខាងក្រោម៖

១-ដាក់ពាក្យស្នើសុំបើកដំណើរការឡើងវិញមកគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកគ្រឹះស្ថាន អ.ប.វ. ឡើងវិញ ដើម្បីពិនិត្យវាយតម្លៃក្នុងការផ្តល់ការអនុញ្ញាតបើកឡើងវិញ។

២-ចុះកិច្ចសន្យាជាមួយក្រសួង ធានាថានឹងអនុវត្តឱ្យបាននូវគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ ក្នុងបរិបទនៃជំងឺកូវីដ-១៩ ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣-បង្កើតក្រុមការងារបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ប្រចាំគ្រឹះស្ថាន អ.ប.វ.។

៤-ចាត់តាំងជនបង្គោលចំនួន ២នាក់ ទទួលបន្ទុកការងារទទួលខុសត្រូវ លើការងារទំនាក់ទំនងនិងផ្តល់ព័ត៌មាន។

៥-ចាត់តាំងបុគ្គលិកទទួលបន្ទុកត្រួតពិនិត្យការពាក់ម៉ាស់ វាស់កម្តៅ បាញ់ទឹកអាល់កុល ឬជែលអាល់កុល។

៦-ធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ដែលមានរោគសញ្ញាសង្ស័យ មុនបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ។

៧-រៀបចំបិទផ្សាយរូបភាពអំពីវិធានការ "៣ការពារ" និង "៣កុំ" និងវិធានការសំខាន់ៗរបស់ក្រសួងសុខាភិបាល។

៨-ផ្តល់ស្ថិតិបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត កំពុងបម្រើការងារ ស្នាក់នៅ និងសិក្សា។

៩-ផ្តល់ស្ថិតិបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត បានទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៨៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

១០-ផ្តល់របាយការណ៍ស្វ័យវាយតម្លៃការរៀបចំអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ មកគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកគ្រឹះស្ថាន អ.ប.វ. ឡើងវិញ មុនពេលបើកដំណើរការ។

១១-រៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅតាមគ្រឹះស្ថាន អ.ប.វ. ដូចជា ការរៀបចំថ្នាក់រៀន រោងជាង បន្ទប់ពិសោធន៍ និងមជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព ការរៀចំអន្តេវាសិកដ្ឋាន ការរៀបចំសន្តិសុខ សណ្តាប់ធ្នាប់ ការលើកកម្ពស់សុខភាព ការផ្តល់សេវាកម្មនៅអាហារដ្ឋាន ការអប់រំសុខភាព និងបណ្តុះបណ្តាលអំពីវិធានការបង្ការជំងឺកូវីដ-១៩ ដូចបានកំណត់ក្នុងគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ។

១២-ណែនាំសិក្ខាកាម សិស្ស និស្សិត ចូលរួមអនុវត្តភារកិច្ចដូចមានកំណត់នៅក្នុងគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ។

១៣-ចូលរួមសហការជាមួយគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកគ្រឹះស្ថាន អ.ប.វ. ឡើងវិញ អាជ្ញាធរដែនដី មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត មន្ទីរសុខាភិបាល រាជធានី ខេត្ត សិក្ខាកាម សិស្ស និស្សិត អាណាព្យាបាល វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងដៃគូនានា។

១៤-តាមដានជាប្រចាំរាល់ការវិវត្តន៍ថ្មីៗនៃជំងឺកូវីដ-១៩ ប្រភេទបំប្លែងថ្មីដែលប្រកាសផ្សព្វផ្សាយជាផ្លូវការដោយក្រសួងសុខាភិបាល និងអាជ្ញាធរដែនដី។

១៥-រៀបចំ និងផ្ញើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពនៃជំងឺកូវីដ-១៩ នៅក្នុងគ្រឹះស្ថាន អ.ប.វ. មកគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកគ្រឹះស្ថាន អ.ប.វ. ឡើងវិញ និងអាជ្ញាធរដែនដីឱ្យបានទៀងទាត់។

ទទួលបានសេចក្តីណែនាំនេះ សូម ឯកឧត្តម លោក លោកស្រី ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត នាយក នាយិកា គ្រឹះស្ថាន អ.ប.វ. បុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត អាណាព្យាបាល និងអាជ្ញាធរដែនដី ចូលរួមអនុវត្តតាមខ្លឹមសារខាងលើ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

ថ្ងៃ សុក្រ ២កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែតុលា ឆ្នាំ២០២១

រដ្ឋមន្ត្រី

អ៊ិត សំហេង

កន្លែងទទួល:
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរសុខាភិបាល រាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋាន អ.ប.វ.
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ